ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

BSDA

BUDDHISM FOR SOCIAL DEVELOPMENT ACTION ORGANIZATION

# គោលនយោបាយកន្លែងការងារ គ្មានគ្រឿងញៀន

# Drug-free Workplace Policy

2024

កែប្រែលើកទី៦

## មាតិកា Content ទំព័រ Page

អំពីអង្គការ BSDA..........................................................................................................៣

ប្រការ១.និយមន័យ..........................................................................................................៥

ប្រការ២.សារធាតុដែលត្រូវអនុវត្តចំពោះសេចក្តីបញ្ជាក់នេះ..........................................................................................................៥

ប្រការ៣.នីតិវិធីទូទៅ..........................................................................................................៥

ប្រការ៤.ការខកខានមិនបានបញ្ជូនការពិសោធន៍ពីជាតិស្រវឹង/ថ្នាំខុសច្បាប់តាមការទាមទារ..................៦

ប្រការ៥.កម្មវិធីជំនួយ និងស្តារនីតិសម្បទាជាតិស្រវឹង/ថ្នាំញៀនរបស់និយោជិត..................................៦

# សេចក្ដីផ្ដើម

**សារចារបស់** BSDA

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍសង្គម(BSDA) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៥ ដោយព្រះសង្ឃ ៧អង្គ នៅវត្តនគរបាជ័យ។ក្រសួងមហាផ្ទៃបានទទួលស្គាល់BSDAតាមរយៈលេខ១៦២ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ។ BSDAមិនធ្វើការបម្រើឱ្យគណបក្សនយោបាយណាឬក៏ផ្សព្វផ្សាយពីសាសនារបស់សមាជិកខ្លួនឡើយ។

អង្គការ BSDA គឺផ្ដោតតែលើការអភិវឌ្ឍសង្គម និងជួយប្រជាជនក្រីក្របំផុតដែលកំពុងរស់ក្នុងសហគមន៍ក្រីក្រ។

**អត្តសញ្ញាណ**

ស.ព.អ.ស ជាអង្គការសហគមន៍បានបង្កើតឡើងនៅលើ គោលការណ៍ព្រះពុទ្ធសាសនានៃធម៌មេត្តា ដើម្បីផ្តល់អំណាចដល់ប្រជាជនដែលងាយរងគ្រោះ និងដើម្បីលើកកម្ពស់ការចូលរួមទំនាក់ទំនងល្អក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីរួមចំណែកលុបបំបាត់នៃភាពរងគ្រោះឬក្រីក្រ។

**គុណតម្លៃ**

ជាឫសគល់ក្នុងការបង្រៀនរបស់ព្រះពុទ្ធដោយអនុវត្តធម៌មេត្តាBSDA បានប្រកាន់ខ្ជាប់និងលើក កម្ពស់គុណតម្លៃរបស់ខ្លួនដូចខាងក្រោម:

- បម្រើអ្នកក្រីក្រះកែលម្អជី វភាពរស់នៅរបស់គ្រួសារអ្នកក្រីក្រ។
- **សាមគ្គីភាព**ះកសាង ជំនឿជាក់ ភាពស្មោះត្រង់ និងការគោរពគ្នាដូចជាគ្រួសារ។
- **លទ្ធិប្រជាធិបតេយ្យ**ះលើកកំពស់សំលេងរួមពីសហគមន៍ អ្នកពាក់ព័ន្ធ និងបុគ្គលិក គ្រប់លំដាប់ថ្នាក់នៅក្នុងដំណើរការធ្វើការសេចក្តីសម្រេចអ្វីមួយ។
- **នវានុវត្តន៍**: ការផ្ដល់នូវឱកាសតែមួយគត់សម្រាប់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយបញ្ហារបស់ពួកគេ តាមរយៈព័ត៌មានបច្ចេកវិទ្យាគមនាគមន៍ (ICT) និងការគិតត្រិះរិះពិចារណា។
- **សុចរិតភាព និងគណនេយ្យភាព**ះនៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ! ត្រូវបានទទួលខុសត្រូវខ្ពស់ និងមានតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ។

**ទស្សនៈវិស័យ**

អង្គការ ស.ព.អ.ស ចង់ឃើញសង្គមដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យនិងអាចចិញ្ចឹមជីវិតបានដោយខ្លួនឯង។

**បេសកកម្ម**

ស.ព.អ.ស គឺដើម្បីជំរុញ និងលើកកម្ពស់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះ ជាពិសេសស្ត្រីកុមារ និងយុវជន តាមរយៈវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រាសសង្គម អភិបាលកិច្ចល្អ និងការផ្តួចផ្តើមអភិវឌ្ឍន៍ជីវភាពរស់នៅ និងកម្មវិធីនវានុវត្តន៍ជាដៃគូជាមួយអ្នកផ្សេងៗ។

## ទិសដៅជាយុទ្ធសាស្ត្រ

- អនុវត្តន៍កម្មវិធីចម្រុះ និងប្រកបដោយភាពច្នៃប្រឌិត
- ការបង្កើតទំនាក់ទំនងរឹងមាំ
- ការប្រកបមុខរបររស់នៅប្រកបដោយនិរន្តរភាព
- ការបង្កើតយុទ្ធសាស្ត្រគៀគរថវិកាប្រកបដោយនិរន្តរភាព
- បន្តការរៀន និងរីកចម្រើន
- ការកសាងសមត្ថភាពបុគ្គលិក

## គោលបំណង

ដើម្បីធានានិរន្តរភាព គណនេយ្យភាពតម្លាភាព សុវត្ថិភាពបុគ្គលិកនិងភាពត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## វិសាលភាព

គោលនយោបាយនេះអនុវត្តទៅលើថ្នាក់ដឹកនាំនិងបុគ្គលិករបស់អង្គការសេកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម ទូទាំងប្រទេសកម្ពុជា។

**ប្រការ១.និយមន័យ**

BSDA គឺជាកន្លែងធ្វើការដែលមិនមានគ្រឿងញៀន។

ដូច្នោះ នៅក្នុងកន្លែងការងាររបស់ BSDA ការផលិតដោយខុសច្បាប់ ការចែកចាយ ការឱ្យការកាន់កាប់ ឬការប្រើប្រាស់សារធាតុហាមឃាត់ ត្រូវបានហាមប្រាម។

ខណៈពេលដែល BSDA យល់ថា នយោជិត និងអ្នកដាក់ពាក្យសុំការងារស្ថិតនៅក្រោមការថែរក្សាសុខភាពរាងកាយ ទាមទារនូវការប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា ការរំលោភបំពានលើវេជ្ជបញ្ជានឹងត្រូវប្រឈមការដោះស្រាយដូចការរំលោភបំពានលើការប្រើប្រាស់សារធាតុខុសច្បាប់។

គោលនយោបាយ BSDA គឺត្រូវជួលអ្នកធ្វើការដែលជៀសឆ្ងាយពីថ្នាំខុសច្បាប់ និងការប្រើប្រាស់គ្រឿងស្រវឹង ក្នុងពេលការងារ។ និយោជិតណាដែលប្តេជ្ញាបំពានលើគោលនយោបាយនេះ គឺប្រឈមនឹងការដាក់ពិន័យដែលអាចរួមបញ្ចូលទាំងការបញ្ឈប់កិច្ចសន្យា សូម្បីតែជាការប្រព្រឹត្តលើកទីមួយ។

**ប្រការ២. សារធាតុដែលត្រូវអនុវត្តចំពោះសេចក្តីបញ្ជាក់នេះ**

វាជាស្តង់ដារនៃក្រមសីលធម៌របស់ BSDA ដែលបុគ្គលិកមិនអាចប្រើថ្នាំខុសច្បាប់ និងសេពគ្រឿងស្រវឹង។ ដើម្បីរក្សាក្រមសីលធម៌នេះ BSDA បង្កើត និងរក្សាកម្មវិធី និងវិន័យមួយចំនួនដូចបានកំណត់ខាងក្រោម។

**ក.ថ្នាំខុសច្បាប់**

និយោជិតណាដែលបាននាំយកមកក្នុងបរិវេណ ឬទ្រព្យសម្បត្តិរបស់ BSDA, មានកម្មសិទ្ធិ, នៅក្រោមឥទ្ធិពល, មាននៅក្នុងខ្លួនប្រាណ ឈាម ឬទឹកនោមក្នុងបរិមាណដែលអាចចាប់បាន, ឬប្រើប្រាស់, ទិញ, ជួញដូរ, លក់ ឬមានចេតនាលក់ ឬជួញដូរគ្រប់ទម្រង់នៃថ្នាំខុសច្បាប់ ខណៈពេលបម្រើការងារឱ្យ BSDA ឬគ្រប់ពេលវេលានៅក្នុងចន្លោះពីពេលចាប់ផ្តើម រហូតដល់បញ្ចប់ពេលធ្វើការ ថាតើមានភារកិច្ច ឬអត់ និងថាតើមានភារកិច្ចរបស់ BSDA ឬទ្រព្យសម្បត្តិរបស់ BSDA ឬអត់, គឺមានពិរុទ្ធភាពចំពោះការធ្វើខុស និងត្រូវប្រឈមជាមួយការដាក់ពិន័យ រួមមានការបញ្ឈប់កិច្ចសន្យាភ្លាមៗ ឬការផ្អាកពីការងារភ្លាមៗ ដោយមិនទទួលបានប្រាក់បៀវត៍ សូម្បីតែជាការប្រព្រឹត្តលើកទីមួយក៏ដោយ។

**ខ.ជាតិស្រវឹង**

និយោជិតដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ជាតិស្រវឹងនៅពេលណាក៏ដោយ ខណៈពេលបំពេញភារកិច្ចរបស់ BSDA ឬក្នុងកំឡុងម៉ោងការងារចន្លោះពីពេលចាប់ផ្តើម រហូតដល់បញ្ចប់នៃពេលវេលាបំពេញការងារ ទោះជាមានភារកិច្ច ឬអត់ និងទោះជាធ្វើកិច្ចការរបស់ BSDA ឬប្រើប្រាស់ទ្រព្យសម្បត្តិរបស់ BSDA ឬក៏អត់ គឺមានពិរុទ្ធភាពចំពោះការធ្វើខុស និងត្រូវប្រឈមជាមួយការដាក់ពិន័យ រួមមានការបញ្ឈប់កិច្ចសន្យាភ្លាមៗ ឬការផ្អាកពីការងារភ្លាមៗ ដោយមិនទទួលបានប្រាក់បៀវត៍ សូម្បីតែជាការប្រព្រឹត្តលើកទីមួយក៏ដោយ។

**ប្រការ៣.នីតិវិធីទូទៅ**

BSDA នឹងជូនដំណឹងដោយលាយលក្ខណ៍ជាអក្សរទៅកាន់និយោជិតដែលត្រូវជាប់ទោសចំពោះការរំលោភបំពានបញ្ញាត្តិនៃការប្រើប្រាស់ថ្នាំខុសច្បាប់ ដែលកើតឡើងនៅកន្លែងធ្វើការងារ ដូចរៀបរាប់ខាងក្រោមនេះ៖

និយោជិតដែលត្រូវបានរាយការណ៍អំពីការអន់ថយផ្នែកការងារ ឬមិនអាចបំពេញការងារតាមភារកិច្ចដែលបានទាមទារ ព្រោះតែការប្រើប្រាស់ថ្នាំខុសច្បាប់ ឬជាតិស្រវឹង នឹងមិនត្រូវអនុញ្ញាតឱ្យធ្វើការងារនោះទេ។ ក្នុងករណីនីមួយៗ និយោជិតនឹងត្រូវបានស្នើសុំការអនុញ្ញាតនូវការស្រាវជ្រាវ និង/ឬចូលរួមនូវការពិសោធន៍ពីជាតិស្រវឹង និង/ជាតិថ្នាំខុសច្បាប់។

**ប្រការ៤. ការខកខានមិនបានបញ្ជូនការពិសោធន៍ពីជាតិស្រវឹង/ថ្នាំខុសច្បាប់តាមការទាមទារ**

ការបដិសេធក្នុងការបញ្ជូននូវការស្រាវជ្រាវ ឬទៅធ្វើការពិសោធន៍រកជាតិស្រវឹង/ថ្នាំខុសច្បាប់ នឹងត្រូវបានវិនិច្ឆ័យជាការប្រព្រឹត្តខុសផ្នែកវិន័យ ហើយបុគ្គលិកនឹងទទួលបានលិខិតព្រមានជាលើកទីមួយ។ ការបដិសេធជាលើកទីពីរ នឹងត្រូវចាត់ទុកថាមានចេតនាសុំលាឈប់ ហើយបុគ្គលិកនឹងមានគេជួយក្នុងការប្រមូលសម្ភារៈផ្ទាល់ខ្លួន និងត្រូវបានគេអមដំណើរចេញពីការិយាល័យ ឬកន្លែងការងារក្នុងភូមិ។

**ក.ការទទួលយកការពិសោធន៍ជាតិស្រវឹង/ថ្នាំញៀន វិជ្ជមាន**

និយោជិតដែលធ្វើការពិសោធន៍វិជ្ជមានសម្រាប់ការប្រើប្រាស់ថ្នាំ ឬជាតិស្រវឹង គឺជាការបំពានលើគោលនយោបាយរបស់ BSDA។ និយោជិតនឹងទទួលបានការព្រមានផ្នែកវិន័យពីអ្នកគ្រប់គ្រងធនធានមនុស្ស និងរដ្ឋបាល ហើយត្រូវបានទាមទារឱ្យស្វែងរកការព្យាបាលក្នុងកម្មវិធីស្តារនីតិសម្បទានៃថ្នាំញៀន និងជាតិស្រវឹង ដែលទទួលបានការយល់ព្រម។

និយោជិតដែលបដិសេធ មិនចូលរួមក្នុងកម្មវិធី ឬមិនពេញចិត្តក្នុងការបំពេញ កម្មវិធីស្តារនីតិសម្បទា ឬនៅតែបន្តការរំលោភបំពានគោលនយោបាយនេះ នឹងត្រូវបញ្ឈប់ពី BSDA។

និយោជិតដែលផ្តល់ការបញ្ជាក់ការយល់ព្រម ដោយលាយលក្ខណ៍ជាអក្សរ អំពីការចូលរួមក្នុងកម្មវិធីប្រឹក្សានឹងត្រូវដាក់ក្នុងការសាកល្បងការងាររយៈពេល ៩០ថ្ងៃ។

ប្រសិនបើនយោជិតធ្វើពិសោធន៍ ឃើញភាពវិជ្ជមានសម្រាប់ ការប្រើប្រាស់ថ្នាំញៀន ឬជាតិស្រវឹង ក្នុងរយៈពេល ៩០ថ្ងៃនៃការសាកល្បងការងារ គាត់/នាងនឹងត្រូវបានស្នើសុំឱ្យចាកចេញភ្លាមៗ និងកត់សម្គាល់ចំពោះការបញ្ឈប់នេះដោយការលាយលក្ខណ៍ជាអក្សរពីផ្នែកធនធានមនុស្ស។

**ខ.ការកាន់កាប់ ការប្រើប្រាស់ ឬការចែកចាយថ្នាំខុសច្បាប់**

ការផលិត ការលក់ ការទិញ ការបញ្ជូន ការប្រើប្រាស់ ឬការកាន់កាប់ថ្នាំខុសច្បាប់ដោយនយោជិតក្នុងបរិវេណ BSDA ក្នុងយានយន្ត BSDA ឬខណៈពេលបំពេញការងាររបស់ BSDA គឺត្រូវបានហាមឃាត់ និងផ្តល់លទ្ធផលជាការបញ្ឈប់ភ្លាមៗ។ BSDA ក៏នឹងទាក់ទងជាមួយអ្នកពង្រឹកច្បាប់មូលដ្ឋានដើម្បីទទួលដឹងពីការផលិត ការលក់ ការទិញ ការបញ្ជូន ការប្រើប្រាស់ ឬការកាន់កាប់ថ្នាំខុសច្បាប់ដោយនយោជិតក្នុងបរិវេណ BSDA។

**ប្រការ៥. កម្មវិធីជំនួយ និងស្តារនីតិសម្បទាជាតិស្រវឹង/ថ្នាំញៀន របស់នយោជិត**

BSDA រក្សាព័ត៌មានអំពីកម្មវិធីជំនួយនិយោជិតក្នុងស្រុក និងកម្មវិធីស្តារនីតិសម្បាទាជាតិស្រវឹង/ ថ្នាំខុសច្បាប់ក្នុងស្រុក ដែលអាចជួយនិយោជិត ដែលទទួលរងឥទ្ធិពលពីជាតិស្រវឹង/ការប្រើប្រាស់គ្រឿងញៀន និងគ្រួសាររបស់ពួកគេ។

ទោះបីជាយ៉ាងណាក៏ដោយ វាជាទំនួលខុសត្រូវរបស់និយោជិតម្នាក់ៗក្នុងការស្វែងរកជំនួយពីមួយក្នុងចំណោមកម្មវិធីទាំងនេះ មុនពេលបញ្ហាជាតិស្រវឹង និងថ្នាំញៀននាំទៅដល់សកម្មភាពផ្នែកវិន័យ។

ការសម្រេចចិត្តរបស់និយោជិត ក្នុងការស្វែងរកជំនួយពីកម្មវិធីទាំងនោះ នឹងមិនត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការដាក់ពិន័យនោះទេ និងក៏មិនត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងនឹងនិយោជិតក្នុងដំណើរដាក់វិន័យផ្សេងៗ ហើយ BSDA លើកទឹកចិត្តយ៉ាងខ្លាំងក្លាចំពោះនិយោជិតដែលសង្ស័យថា ពួកគេអាចមានបញ្ហាដើម្បីស្វែងរកជំនួយ។ ផ្ទុយមកវិញការប្រើប្រាស់កម្មវិធីនឹងមិនអាចបញ្ឈប់សកម្មភាពដាក់ពិន័យបានទេនៅពេលប្រឈមនឹងការបង្ហាញពីការរំលោភលើគោលនយោបាយនេះនៅខាងក្រៅកម្មវិធី។

ខ្លឹមសារ ឬបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងគោលនយោបាយខាងលើត្រូវទុកជានិរាករណ៍។

ថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
កំពង់ចាម ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២៤

| | |
|---|---|
| **ហត្ថលេខា** | **ហត្ថលេខា** |
| **ឃឺត ព្រីដេនប៊ឺក** | **ឈុន ស្រស់** |
| Kurt Bredenberg | Chhon Srors |
| **ប្រធានក្រុមប្រឹក្សាភិបាល** | **នាយិកាប្រតិបត្តិ** |
| Chairman of Board of Director | Executive Director |